៥៦

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តកំពង់ធំ

សាលក្រមព្រហ្មទណ្ឌលេខ: ២៧ (ក)

ចុះថ្ងៃទី ០២ ខែ មីនា ឆ្នាំ ២០១០

លេខអយ្យការ: ៣៧៤/២៤.៧.០៧

លេខស៊ើបសួរ: ៣៦០/២៥.៩.០៧

លេខជំនុំជម្រះ: ៤៩/១០.៣.០៩

4/4

តាងនាមប្រជារាស្ត្រខ្មែរ

សាលាដំបូងខេត្តកំពង់ធំ

បង្កើតឡើងតាមច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តីនៃរដ្ឋកម្ពុជាដែលប្រកាសឱ្យប្រើតាមក្រឹត្យលេខ: ០៦ ក្រ ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៣ ។

បានបើកកិច្ចពិភាក្សាចេញសាលក្រមជាសាធារណៈនៅសាលជំនុំជំរះសាលាដំបូងខេត្តកំពង់ធំ នាថ្ងៃទី ០២ ខែ មីនា ឆ្នាំ ២០១០ វេលាម៉ោង ៨.០០ព្រឹក ដោយមានសមាសភាពដូចតទៅ:

ចៅក្រមជំនុំជម្រះ:

លោក [redacted] ចៅក្រមនៃសាលាដំបូងខេត្តកំពង់ធំ

តំណាងអយ្យការ

លោក [redacted] ព្រះរាជអាជ្ញារងសាលាដំបូងខេត្តកំពង់ធំ

ក្រឡាបញ្ជីសវនាការ

លោក [redacted] ក្រឡាបញ្ជីនៃសាលាដំបូងខេត្តកំពង់ធំ

ដើម្បីជំនុំជំរះលើសំណុំរឿងព្រហ្មទណ្ឌលេខ: ៣៧៤ ចុះថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ២០០៧ សំណុំរឿងស៊ើបសួរលេខ ៣៦០ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៧ សំណុំរឿងជំនុំជំរះលេខ: ៤៩ ចុះថ្ងៃទី ១០ ខែ មីនា ឆ្នាំ ២០០៩ របស់សាលាដំបូងខេត្តកំពង់ធំដែលមាន:

ជនជាប់ចោទឈ្មោះ [redacted] អាយុ ៤៣ ឆ្នាំ ភេទ ស្រី ជាតិ ខ្មែរ សាសនា ព្រះពុទ្ធ កើតនៅភូមិ ពោធិ៍តាកក ឃុំ កំពង់ស្វាយ ស្រុក កំពង់ស្វាយ ខេត្ត កំពង់ធំ ទីលំនៅបច្ចុប្បន្នភូមិ កំពង់រទេះ សង្កាត់ កំពង់រទេះ ក្រុង ស្ទឹងសែន ខេត្ត កំពង់ធំ ឪពុកឈ្មោះ [redacted] (ស) ម្តាយឈ្មោះ [redacted] (ស) ប្តីឈ្មោះ [redacted] មានកូន ២នាក់ ទោសពីមុនគ្មាន (ក្រៅឃុំ) ។

ដាក់ក្រោមការពិនិត្យពីបទ: **ឆបោក** ប្រព្រឹត្តនៅភូមិ កំពង់ធំ សង្កាត់ កំពង់រទេះ ក្រុង ស្ទឹងសែន ខេត្ត កំពង់ធំ កាលពីឆ្នាំ ២០០៥ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា ៤៥ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ចុះថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ ១៩៩២ ។

ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] អាយុ ៤៥ ឆ្នាំ ភេទ ស្រី ជាតិ ខ្មែរ សាសនា ព្រះពុទ្ធ មុខរបរ បុគ្គលិកមណ្ឌលសុខភាពខេត្តកំពង់ធំ កើតនៅភូមិ បារាយណ៍ ឃុំ បារាយណ៍ ស្រុក បារាយណ៍ ខេត្ត កំពង់ធំ ទីលំនៅបច្ចុប្បន្នភូមិ កំពង់ធំ សង្កាត់ កំពង់រទេះ ក្រុង ស្ទឹងសែន ខេត្ត កំពង់ធំ ឪពុកឈ្មោះ [redacted] (ស) ម្តាយឈ្មោះ [redacted] (ស) ប្តីឈ្មោះ [redacted] មានកូន ៣ នាក់ ទោសពីមុនគ្មាន ។

**ការប្រព្រឹត្តរបស់ជនជាប់ចោទមានដូចតទៅ**

ក្នុងអំឡុងឆ្នាំ ២០០០ ជនជាប់ចោទឈ្មោះ [redacted] បានធ្វើជាមេតុងទីនដែលមានសមាជិកចំនួនជាង ១៨ នាក់ក្នុងនោះមានក្បាលចំនួន ៥០០០០រៀល និងក្បាល ១០០០០០រៀលគូះ ដែលកេនសមាជិក១-ឈ្មោះ [redacted] ចំនួន ២ ៥០០ ០០០ រៀល ២-ឈ្មោះ [redacted] ចំនួន ២ ៥០០ ០០០ រៀល ៣-ឈ្មោះ [redacted] ចំនួន ៧ ៨៥០.០០០ រៀល ៤-ឈ្មោះ [redacted] ចំនួន ១ ៧០០ ០០០ រៀល ៥-ឈ្មោះ [redacted] ចំនួន ១ ៣០០ ០០០ រៀល ៦-ឈ្មោះ [redacted] ចំនួន ១.៦០០.០០០ រៀល ៧-ឈ្មោះ [redacted] ចំនួន ២ ០០០ ០០០ រៀល ៨-ឈ្មោះ [redacted] ចំនួន ១លាន រៀល ៩-ឈ្មោះ [redacted] ចំនួន ២.៣០០ ០០០ រៀល ១០-ឈ្មោះ [redacted] ចំនួន ៣ ០០០ ០០០ រៀល ១១-ឈ្មោះ [redacted] ចំនួន ១ ៩៥០ ០០០ រៀល ១២-ឈ្មោះ [redacted] ចំនួន ១ ៩៥០ ០០០ រៀល ១៣-ឈ្មោះ [redacted] ចំនួន ៦ ១០០.០០០ រៀល ១៤-ឈ្មោះ [redacted] ចំនួន ៧ ០០០.០០០ រៀល ១៥-ឈ្មោះ [redacted] ចំនួន ៦.៩៥០.០០០ រៀល ១៦-ឈ្មោះ [redacted] ចំនួន ១ ០០០ ០០០ រៀល ១៧-ឈ្មោះ [redacted] ចំនួន ៣ ០០០ ០០០ និង១៨-ឈ្មោះ [redacted] ចំនួន ៧.១០០.០០០ រៀល ។

Scanned by CamScanner

ក្រោយពីប្រមូលប្រាក់តុងទីនរួចមកជនជាប់ចោទបានប្រើល្បិចកលដោយភូតទៅលើសមាជិកថា សមាជិកនេះដេញបាន សមាជិកនោះដេញបានជាបន្តបន្ទាប់ លុះដល់ថ្ងៃខែមិនចាំឆ្នាំ ២០០៤ ជនជាប់ចោទឈ្មោ[redacted]ានធ្វើការគេចខ្លួន ដោយពុំបានទូទាត់ប្រាក់ដល់សមាជិកកូនតុងទីនដែលនៅសល់នោះទេ ។

បានឃើញដីកាសន្និដ្ឋានស្ថាពរលេខ:២១០ អក/០៩ ចុះថ្ងៃទី ០២ ខែ មីនា ឆ្នាំ ២០០៩ របស់តំណាងអយ្យការអមសាលាដំបូងខេត្តកំពង់ធំ សម្រេចចោទប្រកាន់លើឈ្មោ[redacted]អាយុ ៤៣ ឆ្នាំ ពីបទ: ឆបោក តាមមាត្រា ៤៥ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ចុះថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ ១៩៩២ ។

បានឃើញដីកាបញ្ជូនរឿងទៅជំនុំជំរះលេខ: ៩៣/២០០៩ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០៩ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តកំពង់ធំ ។

បានឃើញដីកាចាត់តាំងចៅក្រមជំនុំជម្រះលេខ: ៥៦/០៩ ចុះថ្ងៃទី ១០ ខែ មីនា ឆ្នាំ ២០០៩ របស់ប្រធានសាលាដំបូងខេត្តកំពង់ធំ ។

តំណាងអយ្យការធ្វើសន្និដ្ឋានថា: ឆ្លងតាមការសួរដេញដោលពេលនេះ តំណាងអយ្យការនៅតែប្តឹងសុំឱ្យលោកចៅក្រមពិនិត្យពិចារណា និងសំរេចឱ្យរួចខ្លួនពីបទចោទប្រកាន់ឈ្មោះខាងលើនេះតាមច្បាប់ ។

-ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ

-ក្រោយពីបានស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី

-ក្រោយពីបានពិនិត្យភស្តុតាង និងឯកសារនានា

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ

-ក្រោយពីបានពិនិត្យ ពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

**<u>សាលាដំបូងខេត្តកំពង់ធំ</u>**

**យល់ឃើញថា**

តំណាងអយ្យការបានធ្វើការចោទប្រកាន់លើជនជាប់ចោទឈ្មោះ[redacted]បទ: ឆបោក ប្រព្រឹត្តនៅភូមិកំពង់ធំ សង្កាត់ កំពង់រទេះ ក្រុង ស្ទឹងសែន ខេត្ត កំពង់ធំ កាលពីឆ្នាំ ២០០៥ គប្បីតុលាការពិចារណាសំរេចលើកយកបទចោទប្រកាន់នេះមកជំនុំជំរះបាន ដោយហេតុថា ករណីនេះស្ថិតក្នុងរង្វង់ដែនសមត្ថកិច្ចសាលាដំបូងខេត្តកំពង់ធំ ។

ជនជាប់ចោទឈ្មោ[redacted]ជាទីតិជនមានទីតិសម្បទាបរិបូរណ៍ដោយពុំមានសញ្ញាណណាមួយដែលនាំឱ្យកោតមន្ទិលសង្ស័យថាជននេះមានបញ្ហាវិបល្លាសស្មារតីក្នុងពេលប្រព្រឹត្តបទល្មើសនោះឡើយ ។

តាមចម្លើយជនជាប់ចោទឈ្មោ[redacted]ះ បានឆ្លើយថា: ខ្ញុំធ្វើជាមេតុងទីនតាំងពីឆ្នាំ ២០០១-២០០២ មកម្ល៉េះ លុះដល់ថ្ងៃខែមិនចាំឆ្នាំ ២០០៤ កូនតុងទីនដេញបានប្រាក់ជាងមួយលានរៀលក៏រត់បាត់រហូតបច្ចុប្បន្ន សមាជិកដែលរត់មានចំនួន០៧នាក់ ។ ដើម្បីរកប្រាក់សងកូនតុងទីនដែលដេញបានក្រោយ ខ្ញុំបានដេញយកប្រាក់មានសមាជិក ២១ និង ២២ នាក់យកទៅសងជំនួសសមាជិកដែលរត់នោះ ។ លុះដល់ថ្ងៃទី ១០-១-០៧ ខ្ញុំបានសុំច្បាប់ទៅមើលម្តាយក្មេកឈឺនៅរកាជួរស្រុកសណ្តាន់ពីរថ្ងៃក្រោយមកគេចោទថា ខ្ញុំរត់ចោលសមាជិកតុងទីន ។ ចំពោះប្រាក់សំណងដែលដើមបណ្តឹងទាំង១៨នាក់ប្តឹងទាមទារនោះខ្ញុំសុំសងជាបីដំណាក់កាល តែបើឱ្យខ្ញុំសងឱ្យអស់ក្នុងរយៈពេលបីខែនោះខ្ញុំពុំមានលទ្ធភាពសងទេ ។ ខ្ញុំសុំសងក្នុងម្នាក់១១ខែចំនួន១ម៉ឺនរៀលរហូតដល់សងគ្រប់ចំនួនទាំងអស់គ្នា ។

ស្របតាមចម្លើយខាងលើនេះដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted]បានឆ្លើយថា:ឈ្មោះ ស៊ិន ចន្ថារ៉ុច បានបើរប្រមូលប្រាក់ពីសមាជិកតុងទីនដែលមានខ្ញុំជាកូនហើយតុងទីននោះមានចំនួន១៨ក្បាលគឺក្បាល៥ម៉ឺនរៀលខ្លះនិងក្បាល១០ម៉ឺនរៀលខ្លះ ។ ចាប់ផ្តើមលេងពីឆ្នាំ ២០០០ មកដល់ឆ្នាំ ២០០៤ ដល់ពេលកំណត់ដេញម្តង១ស្រេចតែឈ្មោះ[redacted]ឆ្លើយថា: ឈ្មោះនេះដេញបាន ឈ្មោះនោះបន្តបន្ទាប់រៀងរាល់ខែ តាមការពិតពុំមានសមាជិកណាមួយដេញបានទេ ប្រាក់ដែលប្រមូលបានពីសមាជិករៀងរាល់ខែនោះគឺយកមកធ្វើជាប្រយោជន៍ផ្ទាល់ខ្លួនទាំងអស់ ។

ពិនិត្យលើសកម្មភាពជាក់ស្តែងអាចបង្ហាញឱ្យឃើញនូវកត្តាផ្លូវចិត្តរបស់ជនជាប់ចោទថា ជននេះបានយល់ដឹងយ៉ាងច្បាស់នៃទង្វើរបស់ខ្លួនដែលបានប្រើប្រាស់ឧបាយកលទុច្ចរិតដើម្បីឱ្យជនរងគ្រោះប្រគល់ប្រាក់ចំនួន ៦០ ៤០០ ០០០ រៀលមកឱ្យខ្លួន ពោលគឺ ព្យសនកម្មទាំងនេះគឺជាបច្ច័យដែលកើតចេញពីឆន្ទៈពិតប្រាកដរបស់ជនជាប់ចោទក្នុងចេតនាទុច្ចរិតដើម្បីយកប្រាក់របស់ជនរងគ្រោះមកធ្វើជាប្រយោជន៍ផ្ទាល់ខ្លួន ។

Scanned by CamScanner

ជនជាប់ចោទបានយល់ដឹងយ៉ាងច្បាស់ថា ប្រាក់ចំនួន ៦០.៤០០.០០០រៀល គឺជាទ្រព្យសម្បត្តិផ្ទាល់ខ្លួនរបស់ជនរង គ្រោះ ហើយនៅតែមានចេតនាចង់បានប្រាក់ទាំងនេះមកធ្វើជាទ្រព្យសម្បត្តិផ្ទាល់ខ្លួន ផ្ទុយពីឆន្ទៈរបស់ជនរងគ្រោះ។

ភស្តុតាងផ្អែកសត្យានុម័ត និងអត្តនោម័តរបស់ជនជាប់ចោទ អាចឱ្យតុលាការសន្និដ្ឋានបានថា ជនជាប់ចោទពិតជាបានប្រព្រឹត្តបទល្មើសក្នុងតំណាក់កាលបានសម្រេច ។

គ្រប់សកម្មភាពរបស់ជនជាប់ចោទ រួមទាំងកត្តាផ្លូវចិត្តដែលស្តែងចេញជាអំពើជាក់ស្តែងតាមរយៈចម្លើយសារភាពរបស់ជនជាប់ចោទព្រមទាំងការឆ្លើយឱ្យការរបស់ជនរងគ្រោះឃើញថា ពិតជាមានអំពើឆបោក យ៉ាងប្រាកដ ។

ចម្លើយរបស់ជនរងគ្រោះ ពិតជាមានភាពស៊ីសង្វាក់ទៅនឹងចម្លើយសារភាពរបស់ជនជាប់ចោទ និងរបាយការណ៍របស់មន្ត្រីនគរបាលយុត្តិធម៌ ព្រមទាំងវត្ថុតាងដែលរឹបអូសបានដែលបញ្ជាក់ឱ្យឃើញថា ពិតជាមានអំពើឆបោក កើតឡើងកាលពីឆ្នាំ ២០០៥ នៅភូមិ កំពង់ធំ សង្កាត់ កំពង់រទេះ ក្រុង ស្ទឹងសែន ខេត្ត កំពង់ធំ ដែលបង្កឡើងដោយជនជាប់ចោទប្រាកដមែន។

រាល់ភស្តុតាងដែលប្រមូលបានអាចកំណត់ឱ្យឃើញថាជនជាប់ចោទឈ្មោ[redacted]តជាចារីក្នុងបទល្មើសឆបោក ដែលមានចេតនាទុច្ចរិតក្នុងការធ្វើឱ្យជនរងគ្រោះមានការខាតបង់ប្រាក់អស់មួយចំនួន កាលពីឆ្នាំ ២០០៥ នៅភូមិតាឧក ឃុំ បល្ល័ង្ក ស្រុក បារាយណ៍ ខេត្ត កំពង់ធំ ពិតប្រាកដមែន។

មានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់លើឈ្មោ[redacted]បទៈ ឆបោក ប្រព្រឹត្តនៅភូមិ កំពង់ធំ សង្កាត់ កំពង់រទេះ ក្រុង ស្ទឹងសែន ខេត្ត កំពង់ធំ កាលពីឆ្នាំ ២០០៥ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា ៤៥ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ចុះថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ ១៩៩២ ។

ដើមបណ្តឹងឈ្មោ[redacted]ឈ្មោ[redacted]ឈ្មោះ[redacted]ឈ្មោះ [redacted]ឈ្មោះ[redacted] ឈ្មោះ [redacted]ឈ្មោ[redacted]ឈ្មោះ[redacted]ឈ្មោះ [redacted] ឈ្មោ[redacted]ឈ្មោះ[redacted]ឈ្មោះ [redacted] ឈ្មោ[redacted]ឈ្មោះ[redacted]ឈ្មោះ[redacted]ឈ្មោះ [redacted] បានផ្ទេរសិទ្ធិឱ្យឈ្មោះ [redacted]ងទាមទារប្រាក់សរុបចំនួន ៦០.៤០០.០០០ រៀល និងជម្ងឺចិត្តសរុបជាប្រាក់ចំនួន ១៦.៥០០.០០០ រៀល តុលាការចាត់ទុកថាឈ្មោះ[redacted]នប្រកាសខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីទាមទារការខូចខាត និងសំណងជំងឺចិត្ត គប្បីតុលាការពិចារណាពីព្យសនកម្មនេះ ។

ក្រោយពីជនជាប់ចោទប្រមូលបានប្រាក់ពីជនរងគ្រោះដែលមានគ្នាចំនួន១៨នាក់រួចមកគេចខ្លួនរហូត ដោយពុំកេះការសងប្រាក់ទៅជនរងគ្រោះនោះទេ ហើយម្យ៉ាងទៀត ជនជាប់ចោទក៏ពុំបានបង្ហាញវត្តមានទាន់តាមពេលវិធីជំនុំជំរះនេះដែរ គប្បីសំរេចចាប់ខ្លួនជននេះ។

ជនជាប់ចោទខាងលើមានសមត្ថភាពនិងចំណេះដឹងតិចតួច មានជីវភាពក្រីក្រ ខ្វះការពិចារណានូវទង្វើប្រព្រឹត្តរបស់ខ្លួន គប្បីតុលាការពិចារណាពីស្ថានសំរាលទោស។

ការប្រព្រឹត្តរបស់ជនជាប់ចោទបានបង្កឱ្យមានផលប៉ះពាល់ដល់សណ្តាប់ធ្នាប់រៀបរយសន្តិសុខ និងនិត្យានុកូលភាពនៃសង្គមជាតិ ប៉ុន្តែមិនធ្ងន់ធ្ងរនោះទេ ។

ជនជាប់ចោទបានសំដែងសំដីចុងក្រោយថាៈ សុំឱ្យតុលាការបន្ធូរបន្ថយទោសដល់ខ្លួន តុលាការនឹងបានលើកយកមកពិចារណាអំពីទណ្ឌកម្ម ។

**ហេតុដូច្នេះសាលាដំបូងខេត្តកំពង់ធំ**

**វិនិច្ឆ័យសេចក្តី**

១-ផ្តន្ទាទោសឈ្មោ[redacted]អាយុ ៤៥ ឆ្នាំ ភេទ ប្រុស ជាតិ ខ្មែរ កំណត់ដាក់ពន្ធនាគាររយៈពេល ២ ឆ្នាំ ពីបទៈ ឆបោក ប្រព្រឹត្តនៅភូមិ កំពង់ធំ សង្កាត់ កំពង់រទេះ ក្រុង ស្ទឹងសែន ខេត្ត កំពង់ធំ កាលពីឆ្នាំ ២០០៥ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា ៤៥ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ចុះថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ ១៩៩២។

២-បង្គាប់ឱ្យចាប់ខ្លួនឈ្មោ[redacted]ក្នុងពេលនេះតែម្តង ។

៣-បង្គាប់ឱ្យសងសំណង និងជំងឺចិត្តចំនួន ៦០.៤០០.០០០ រៀល និងជម្ងឺចិត្តសរុបជាប្រាក់ចំនួន ១៦.៥០០.០០០ រៀល ឱ្យទៅដើមបណ្តឹងរដ្ឋប្បវេណីដែលមានឈ្មោះ[redacted]ល្មមពរលើសពីនេះត្រូវបដិសេធចោល ដែលក្នុងនោះត្រូវសងទៅ:

ឈ្មោះ[redacted]នួន ២ ៥០០ ០០០ រៀល និងជម្ងឺចិត្តចំនួន ៥០ ០០០០ រៀល។

Scanned by CamScanner

4

-ឈ្មោះ[redacted]ំនួន ២.៥០០.០០០ រៀល និងជម្ងឺចិត្តចំនួន ១.០០០.០០០ រៀល ។

-ឈ្មោះ[redacted]ចំនួន ៧.៨៥០.០០០ រៀល និងជម្ងឺចិត្តចំនួន ៣.០០០.០០០ រៀល ។

-ឈ្មោះ[redacted]ចំនួន ១.៧០០.០០០ រៀល និងជម្ងឺចិត្តចំនួន ១០ ០០០០ រៀល ។

-ឈ្មោ[redacted]ំនួន ១.៣០០.០០០ រៀល និងជម្ងឺចិត្តចំនួន ៥០ ០០០០ រៀល ។

-ឈ្មោះ [redacted]ំនួន ១.៦០០.០០០ រៀល និងជម្ងឺចិត្តចំនួន ១០.០០០០ រៀល ។

-ឈ្មោះ[redacted]ចំនួន ២.០០០.០០០ រៀល និងជម្ងឺចិត្តចំនួន ១០.០០០០ រៀល ។

-ឈ្មោះ [redacted]ចំនួន ១.០០០.០០០ រៀល និងជម្ងឺចិត្តចំនួន ១០.០០០០ រៀល ។

-ឈ្មោះ [redacted] ចំនួន ២.៣០០.០០០ រៀល និងជម្ងឺចិត្តចំនួន ១០.០០០០ រៀល ។

-ឈ្មោ[redacted]ចំនួន ៣.០០០.០០០ រៀល និងជម្ងឺចិត្តចំនួន ១.០០០.០០០ រៀល ។

-ឈ្មោះ[redacted]ចំនួន ១.៩៥០.០០០ រៀល និងជម្ងឺចិត្តចំនួន ១.០០០.០០០ រៀល ។

-ឈ្មោះ [redacted]ចំនួន ១.៩៥០.០០០ រៀល និងជម្ងឺចិត្តចំនួន ១.០០០.០០០ រៀល ។

-ឈ្មោះ[redacted]ចំនួន ៦.១០០.០០០ រៀល និងជម្ងឺចិត្តចំនួន ៣.០០០.០០០ រៀល ។

-ឈ្មោះ [redacted]នួន ៧.០០០.០០០ រៀល និងជម្ងឺចិត្តចំនួន ២.០០០.០០០ រៀល ។

-ឈ្មោះ [redacted]នួន ៦.៥៥០.០០០ រៀល និងជម្ងឺចិត្តចំនួន ៣.០០០.០០០ រៀល ។

-ឈ្មោះ [redacted]ចំនួន ១.០០០.០០០ រៀល និងជម្ងឺចិត្តចំនួន ១០.០០០០ រៀល ។

-ឈ្មោះ [redacted]នួន ៣.០០០.០០០ រៀល និងជម្ងឺចិត្តចំនួន ១០.០០០០ រៀល ។

-ឈ្មោះ [redacted] ចំនួន ៧.១០០.០០០ រៀល និងជម្ងឺចិត្តចំនួន ២០.០០០០ រៀល ។

៤-សាលក្រមនេះជំនុំជម្រះ និងប្រកាសជាសាធារណៈ កំបាំងមុខតូភាគី បើកសិទ្ធឱ្យប្តឹងទាស់ក្នុងរយពេល១៥ថ្ងៃ គិតចាប់ពីថ្ងៃទទួលដីកាពីសាលក្រមកំបាំងមុខ និងប្តឹងឧទ្ធរណ៍ក្នុងរយៈពេល១ខែ គិតចាប់ពីថ្ងៃផុតបណ្តឹងទាស់។

ក្រឡាបញ្ជីសវនាការ

[redacted]

ចៅក្រមជំនុំជំរះ